# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ ស្តីពីលទ្ធផលនៃការបោះឆ្នោតទុកចិត្តលើការតែងតាំងអគ្គសវនករ ចំនួន ០១ រូប និងអគ្គសវនកររង ចំនួន ០២ រូប នៃអាជ្ញាធរសវនកម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងអគ្គសវនករ ចំនួន ០១ រូប និងអគ្គសវនកររង ចំនួន ០២ រូប នៃអាជ្ញាធរសវនកម្មជាតិ ដែលមានសមាសភាព ដូចតទៅ :

១- លោកជំទាវ **សោម គីមសួគ៌** ជាអគ្គសវនករ
២- ឯកឧត្តម **ឆាយ គីម** ជាអគ្គសវនកររង
៣- ឯកឧត្តម **សួន សិទ្ធី** ជាអគ្គសវនកររង ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី២០ ខែ តុលាឆ្នាំ ២០១១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៧ រស. ១១១០. ៩៥២

លេខ ៩៦០ ច.ល
បានចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ១០ ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
សុខា